# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ឆ្នាំង

សំណុំរឿងព្រហ្មទណ្ឌលេខ ៤៦២១
ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ ២០២១
សាលក្រមលេខ ១២៨ "ឃ"
ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ ២០២២

## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកំពង់ឆ្នាំង

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ២០២២ វេលាម៉ោង ០៨ និង៣០ នាទីព្រឹក ដោយមានសមាសភាព៖

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកំពង់ឆ្នាំងប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោក ចៅក្រមសាលាដំបូងខេត្តកំពង់ឆ្នាំង ចៅក្រមប្រឹក្សា

លោកស្រី [redacted] ចៅក្រមសាលាដំបូងខេត្តកំពង់ឆ្នាំង ចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកំពង់ឆ្នាំង

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ឆ្នាំង

### ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ ៤៦២១ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ៖

១. ឈ្មោះ [redacted] ខុម ភេទប្រុស អាយុ៤១ឆ្នាំ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរកសិករ ទីកន្លែងកំណើត [redacted] ខេត្តឧត្តរមានជ័យ ទីលំនៅមុនពេលឃាត់ខ្លួននៅភូមិជ្រៃ ឃុំកណ្ដែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] ខុង (រស់) ម្ដាយឈ្មោះ [redacted] ឿឿន (ស្លាប់) ប្រពន្ធឈ្មោះ [redacted] លំ មានកូន ០១នាក់ ប្រវត្តិនៃការផ្ដន្ទាទោស ធ្លាប់ជាប់ពន្ធនាគាររយៈពេល១៧ឆ្នាំនៅប្រទេសថៃ ពីបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន។

ឃាត់ខ្លួនថ្ងៃទី ២៩ ខែតុលា ឆ្នាំ ២០២១

ឃុំខ្លួនថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ ២០២១

២. ឈ្មោះ [redacted] នឿត ភេទប្រុស អាយុ៤២ឆ្នាំ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរកសិករ ទីកន្លែងកំណើត [redacted] ខេត្តឧត្តរមានជ័យ ទីលំនៅមុនពេលឃាត់ខ្លួនភូមិជ្រៃ

ឃុំកណ្ដែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] អាត (រស់) ម្ដាយឈ្មោះ [redacted] កែវ (រស់) ប្រពន្ធឈ្មោះ [redacted] បុផ្ផា មានកូនបីនាក់ ប្រវត្តិនៃការផ្ដន្ទាទោសពីមុនគ្មាន។

ឃាត់ខ្លួនថ្ងៃទី ២៩ ខែតុលា ឆ្នាំ ២០២១

ឃុំខ្លួនថ្ងៃទី ០២ ខែវិច្ឆិកា ឆ្នាំ ២០២១

៣. ឈ្មោះ [redacted] **សត្យា** ភេទស្រី អាយុ៣៨ឆ្នាំ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរនៅផ្ទះ ទីកន្លែងកំណើតនៅ[redacted] រាជធានីភ្នំពេញ ទីលំនៅមុនពេលឃាត់ខ្លួនភូមិជ្រៃ ឃុំកណ្ដែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] សូម៉ា (ស) ម្ដាយឈ្មោះ [redacted] នៀន សម្បត្តិ(រស់) នៅលីវ ប្រវត្តិនៃការផ្ដន្ទាទោសពីមុនគ្មាន។

ឃាត់ខ្លួនថ្ងៃទី ២៩ ខែតុលា ឆ្នាំ ២០២១

ឃុំខ្លួនថ្ងៃទី ០២ ខែវិច្ឆិកា ឆ្នាំ ២០២១

៤.ឈ្មោះ [redacted] **ខាំសែ ហៅ** [redacted] **ហេង** ភេទប្រុស អាយុ៥២ឆ្នាំ សញ្ជាតិថៃ សាសនាព្រះពុទ្ធ មុខរបរកសិករ ទីកន្លែងកំណើតនៅ[redacted] ខេត្តសៀមរាប ទីលំនៅមុនពេលឃាត់ខ្លួនភូមិជ្រៃ ឃុំកណ្ដែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប ប្រវត្តិនៃការផ្ដន្ទាទោសពីមុនគ្មាន។

ឃាត់ខ្លួនថ្ងៃទី ២៩ ខែតុលា ឆ្នាំ ២០២១

ឃុំខ្លួនថ្ងៃទី ០២ ខែវិច្ឆិកា ឆ្នាំ ២០២១

៥.ឈ្មោះ[redacted] **សេងលី** ភេទប្រុស អាយុ៣៨ឆ្នាំ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរកសិករ ទីកន្លែងកំណើតនៅ[redacted] ខេត្តកំពង់ស្ពឺ ទីលំនៅមុនពេលឃាត់ខ្លួនភូមិជ្រៃ ឃុំកណ្ដែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] សល់ (រស់) ម្ដាយឈ្មោះ [redacted] មឿន (រស់) នៅលីវប្រវត្តិនៃការផ្ដន្ទាទោសពីមុនគ្មាន។

ឃាត់ខ្លួនថ្ងៃទី ២៩ ខែតុលា ឆ្នាំ ២០២១

ឃុំខ្លួនថ្ងៃទី ០២ ខែវិច្ឆិកា ឆ្នាំ ២០២១

ពីបទ: **រក្សាទុក ដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្នុងប្រទេសកម្ពុជា អំឡុងឆ្នាំ២០១៨ រហូតដល់ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

លោកមេធាវី [redacted] មេធាវីការពារសិទ្ធិជនជាប់ចោទឈ្មោះ [redacted] **សេងលី**

លោកស្រីមេធាវី [redacted] ជាមេធាវីការពារសិទ្ធិជនជាប់ចោទឈ្មោះ [redacted] **សត្យា**

លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិជនជាប់ចោទ ឈ្មោះ [redacted] ខាំសែ, [redacted] នឿត និងឈ្មោះ [redacted] ខុម

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ១៥២៤ អ.យ.ទ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ ២០២៣ ដ.ដ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ សាលក្រមព្រហ្មទណ្ឌចាត់របៀបលេខ ៣៦ (ឃ) ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង។

## អង្គហេតុដែលប្តឹងមកតុលាការមានដូចតទៅ

កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង១០ និង៣០នាទី សមត្ថកិច្ចនគរបាលការិយាល័យនីតិវិធី (ក៧) នៃមន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន បានចុះបង្ក្រាបបទល្មើសរក្សាទុក ដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន នៅចំណុចស្ថានីយ៍ប្រេងឥន្ធនៈភីធីធី (PTT) ផ្លូវវិមានឈ្នះ១ (ផ្លូវទំនប់ស្រូវ) សង្កាត់ចោមចៅ៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឃាត់ខ្លួនជនត្រូវចោទចំនួន០២នាក់ មានឈ្មោះ [redacted] នឿត ភេទប្រុស និងឈ្មោះ [redacted] ខុម ភេទប្រុស ដកហូតបានវត្ថុតាងគ្រឿងញៀនប្រភេទមេតំហ្វីតាមីន ប្រភេទភេទគ្រាប់ក្រហមមានសញ្ញាអក្សរ WY ចំនួន ០៤កញ្ចប់ (ធំ០៣ និងតូច០១) សមត្ថកិច្ចបានធ្វើការសាកសួរ ទើបដឹងថាមានមេក្លោងនៅខេត្តសៀមរាប រហូតដល់វេលាម៉ោង១៧ និង០៥នាទី នាថ្ងៃដដែល នៅចំណុចផ្ទះគ្មានលេខ ផ្លូវលំ ភូមិជ្រៃ ឃុំកណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប សមត្ថកិច្ចបានបន្តឃាត់ខ្លួនមេក្លោង និងបក្ខពួករបស់ជនត្រូវចោទចំនួន ០៣ នាក់ទៀតរួមមាន៖ ឈ្មោះ [redacted] សត្យា ភេទស្រី ឈ្មោះ [redacted] ខាំសៃ ហៅ [redacted] ហេង ភេទប្រុស ជនជាតិថៃ សញ្ជាតិថៃ និងឈ្មោះ [redacted] សេងលី ភេទប្រុស និងបានដកហូតវត្ថុតាងជាគ្រឿងញៀនមេតំហ្វីតាមីនប្រភេទគ្រាប់មានសញ្ញាអក្សរ WY បន្ថែមចំនួន០៥កញ្ចប់ធំ។ សមត្ថកិច្ចបាននាំជនត្រូវចោទចំនួន០៣នាក់ មកការិយាល័យប្រឆាំងគ្រឿងញៀន ធ្វើការសាកសួរបន្ថែម។ សរុបថ្នាំគ្រាប់ពណ៌ក្រហម (WY) មានទម្ងន់ សរុប ៥០៧៥,៧៩ ក្រាម (ប្រាំគីឡូនិងចិតសិបប្រាំក្បៀសចិតសិបប្រាំបួនក្រាម) ជាប្រភេទមេតំហ្វីតាមីន។ ក្រោយពីការធ្វើការសាកសួរទទួលបានលទ្ធផលថាជនត្រូវចោទ [redacted] សត្យា ក្នុងឆ្នាំ២០១៨ ខ្លួនបានស្គាល់ឈ្មោះ [redacted] យ៉ាត់ ភេទប្រុស ភេទប្រុស ... នៅពេលរកស៊ីជួញឈើជាមួយគ្នា ហើយបានបែកគ្នារហូតដល់ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ ដោយឈ្មោះ [redacted] យ៉ាត់ បានទូរស័ព្ទមកខ្លួន ហើយបាននិយាយពីការលក់ថ្នាំញៀន

មេតំហ្វេតាមីនប្រភេទគ្រាប់ ពីប្រទេសថៃមកកម្ពុជា។ លុះដល់ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២១ ខ្លួនបានឱ្យឈ្មោះ [redacted] នឿត ឡើងទៅប្រទេសថៃ ទៅជួបឈ្មោះ [redacted] យ៉ាត់ ដើម្បីទៅយកថ្នាំញៀនប្រភេទគ្រាប់ ០៨ សុង ស្មើចំនួន ២៥ កញ្ចប់តូច ពីប្រទេសថៃមកកម្ពុជា។ លុះដល់ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២២១ មានម៉ូយម្នាក់នៅភ្នំពេញបានទូរស័ព្ទមកខ្លួនកម្មង់ទិញថ្នាំញៀនពីខ្លួនចំនួន ១០ប្រអប់ ខ្លួនបានឱ្យបក្ខពួកឈ្មោះ [redacted] នឿត និងឈ្មោះ [redacted] ខុម យកថ្នាំញៀននោះទៅឱ្យម៉ូយនៅភ្នំពេញ។ ស្រាប់តែនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ សមត្ថកិច្ចបាននាំបក្ខពួកខ្លួនឈ្មោះ [redacted] នឿត និងឈ្មោះ [redacted] ខុម មកដល់ផ្ទះធ្វើការឃាត់ខ្លួន និងមក្ខពួកខ្លួនមានឈ្មោះ [redacted] ខាំសែ ហៅ [redacted] ហេង និងឈ្មោះ [redacted] សេងលី ភេទប្រុស។ បន្ទាប់មកសមត្ថកិច្ចបានកសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធីច្បាប់។

## នាពេលសវនាការ

ជនជាប់ចោទឈ្មោះ [redacted] សត្យា បានឆ្លើយថា កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ វេលាម៉ោងប្រហែល៤ ទៅ ៥ល្ងាច ខ្លួនកំពុងអង្គុយនៅរានហាលមុខផ្ទះ ពេលនោះសមត្ថកិច្ចចំនួន បីនាក់បានដោះចូលមកក្នុងផ្ទះរបស់ខ្លួន ហើយយកកាំភ្លើងភ្ជង់ខ្លួនឱ្យនៅស្ងៀមខ្លួនបានសួរទៅ សមត្ថកិច្ចថា ហេតុអ្វីបានជាចូលមកក្នុងផ្ទះរបស់ខ្លួន ដោយមិនបានជូនដំណឹង សមត្ថកិច្ចក៏បានឆ្លើយជាមួយ នឹងខ្លួនវិញថា ឱ្យខ្លួនឡើងទៅលើដើម្បីធ្វើការឆែកឆេរ ខ្លួនក៏បានជូនគាត់ ឡើងទៅបន្ទប់របស់ខ្លួនដើម្បីធ្វើការឆែកឆេរ ហើយសមត្ថកិច្ចគាត់បានឡើងទៅបន្ទប់របស់ខ្លួនមុនចំនួន០៣នាក់។ ខ្លួនក៏បាននិយាយថា ហេតុអ្វីបានជាចូលទៅក្នុងបន្ទប់របស់ខ្លួនមុនមិនរង់ចាំខ្លួនសិន។ ពេលនោះសមត្ថកិច្ចបាននិយាយថា កុំនិយាយតមាត់អី ហើយសមត្ថកិច្ចបានចាប់ឆែកឆេរក្នុងបន្ទប់របស់ខ្លួន ហើយរកឃើញថង់ មួយនៅក្នុងទូខោអាវរបស់ខ្លួន និងយកកាបូបដាក់គ្រឿងអលង្ការ និងដាក់លុយយកមកចុះក្រោម ហើយបន្តឆែកឆេរនៅបន្ទប់ផ្សេងៗទៀត តែរកពុំឃើញនោះទេ។ នៅពេលចុះមកដល់ក្រោម សមត្ថកិច្ចគាត់បានប្រាប់ខ្លួនថាថង់ដែលដកហូតពីក្នុងទូខោអាវរបស់ខ្លួន ជាគ្រឿងញៀន ពេលនោះខ្លួនបានសួររក កាបូបរបស់ខ្លួន និងបានយកមកបង្ហាញ និងថតឱ្យខ្លួនឃើញមានលុយ និងគ្រឿងអលង្កា និងឯកសារពាក់ព័ន្ធរបស់ខ្លួនមួយចំនួនទៀតរួចបានបញ្ជូនមកអគ្គស្នងការតែម្តង។ នៅពេលដែល សមត្ថកិច្ចចុះទៅចាប់ខ្លួននៅផ្ទះមានគ្នាចំនួនបីនាក់ឈ្មោះ រុត ខាំសែ (ហៅឈ្មោះ លឹម ហេង និងឈ្មោះ [redacted] សេង លី) [illegible]។ ខ្លួនមិនស្គាល់ឈ្មោះ [redacted] យ៉ាត់ នោះទេ។ ខ្លួនមិនមែនជាអ្នកលក់គ្រឿងញៀន នោះទេ ហើយក៏គ្មានម៉ូយណា មកកុម៉ង់ទិញថ្នាំញៀនពីខ្លួនដែរ ថ្នាំញៀនដែលសមត្ថកិច្ចឆែកឆេររកឃើញនោះមិនមែនជារបស់ខ្លួននោះទេ ហើយ ខ្លួនក៏មិនបានរកស៊ីលក់គ្រឿងញៀននោះដែរ ខ្លួនស្គាល់ឈ្មោះ [redacted] ខាំសែ រយៈពេលប្រាំមួយខែមកហើយស្គាល់គ្នា តាមរយៈមិត្តភក្តិនៅប្រទេសថៃ ឈ្មោះ [redacted] ខុម ត្រូវជា

មិត្តភក្តិរបស់ឈ្មោះ [redacted] នឿត ហើយគាត់ទើបតមកស្នាក់នៅ ផ្ទះរបស់ខ្លួនបានប្រហែលជា ០៨ថ្ងៃ តែប៉ុណ្ណោះ រីឯឈ្មោះ [redacted] នឿត ខ្លួនស្គាល់គាត់យូរមកហើយ។ ឈ្មោះ [redacted] ខាំសៃ ជាអ្នកលក់ម្ហូបនៅផ្សារប្រទេសថៃ។ ពេលសមត្ថកិច្ចឃាត់ខ្លួនដកហូតកាបូបរបស់ខ្លួន ហើយនៅក្នុងកាបូបនោះ មានលុយចំនួន ១២០០ (មួយពាន់ពីររយ) ដុល្លារអាមេរិក, គ្រឿងអលង្ការ, កាតធនាគារ, កាតចាក់វ៉ាក់សាំង, ប័ណ្ណបើកបរ និងកាតពេទ្យ ដោយឡែកថង់ខ្មៅដែលសមត្ថកិច្ចដកហូត ហើយអះអាងថាគ្រឿងញៀន ខ្លួនសូមបដិសេធមិនមែនជារបស់ខ្លួននោះទេ។ ខ្លួនសូមបញ្ជាក់ថា ចំពោះថង់ខ្មៅដែលសមត្ថកិច្ចដកហូត ខ្លួនមិនបានដឹងនោះទេ មុនថ្ងៃកើតហេតុ ឈ្មោះ [redacted] ថេង គាត់បានមកផ្ទះរបស់ខ្លួនមានគ្នាចំនួន០៤នាក់ ហើយគាត់បានខ្ចីឡានរបស់ខ្លួនមកភ្នំពេញ។ ក្រោយមក ឈ្មោះ [redacted] ថេង បានទូរស័ព្ទមកឈ្មោះ [redacted] នឿត និងឈ្មោះ [redacted] ខុម ថាត្រូវ ទៅភ្នំពេញតែម្តង ដល់ម៉ោង១២ ឈ្មោះ [redacted] ថេង បានទូរស័ព្ទមកប្រាប់ខ្លួនថា មកដល់ភ្នំពេញ ហើយ ជូនគាត់ពេញមួយថ្ងៃតែម្តង និងជូនគាត់ដាក់ផ្ទះសំណាក់រួច ហើយ។ លុះព្រឹកឡើងឈ្មោះ [redacted] ថេង គាត់បានទូរស័ព្ទមកខ្លួនថានៅទីណា? ពេលនោះខ្លួនបានឆ្លើយថា នៅផ្ទះ ហើយ ខ្លួនសួរគាត់ទៀតថា ពេលណាមកសៀមរាប ខ្លួនចង់ជួបឈ្មោះ [redacted] នឿត និងឈ្មោះ [redacted] ខុម ខ្លួនបានទូរស័ព្ទទៅ ឈ្មោះ [redacted] នឿត តែមិនចូលខ្លួនក៏បានទូរស័ព្ទទៅឈ្មោះ [redacted] ថេង ហើយគាត់បានឆ្លើយថា មិនបាច់ជួបទេ កំពុងធ្វើដំណើរមកជាមួយគ្នាហើយពេលនោះខ្លួនបាននិយាយថា ខ្លួនចេញទៅក្រៅរកទិញម្ហូបសិន។ លុះដល់ម៉ោង ៤ រសៀល ខ្លួនបានទូរស័ព្ទទៅគាត់ តែគាត់មិនលើក លុះដល់ម៉ោងប្រាំ សមត្ថកិច្ច ចុះមកចាប់ខ្លួន។ មុនថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ ខ្លួនបានឃើញឈ្មោះ [redacted] ថង យួរសាក់កាដូ ទៅបន្ទប់របស់គាត់ ប៉ុន្តែខ្លួនមិនបានដឹងថាជាអ្វីនោះទេ ចំពោះទ្វារបន្ទប់ ផ្ទះទាំងអស់របស់ខ្លួន មិនចាក់សោរនោះទេ។

ជនជាប់ចោទឈ្មោះ [redacted] ខាំសៃ (ហៅ ឈីម ឆោខ) បានឆ្លើយថា: ចំពោះចម្លើយនៅសមត្ថកិច្ច ខ្លួនសូមបដិសេធចោលទាំងស្រុង ខ្លួនមិនបានដឹងថាគេសរសេរអ្វីនោះទេ គឺសមត្ថកិច្ចជាអ្នកវាយបង្ខំឱ្យខ្លួនផ្តិតមេដៃ។ សមត្ថកិច្ចឃាត់ខ្លួននៅខេត្តសៀមរាប ពេលដែលខ្លួនកំពុងធ្វើចត្តាឡីស័កនៅផ្ទះ មិនបានដឹងមូលហេតុនៃការចាប់ខ្លួននោះទេ។ នៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង ៥ល្ងាច ខ្លួនកំពុងគេងនៅផ្ទះក្នុងបន្ទប់ទទួលភ្ញៀវរបស់ឈ្មោះ [redacted] សត្យា បន្ទាប់មកក៏មានសមត្ថកិច្ច ចុះមកដល់ហើយធ្វើការឃាត់ខ្លួនតែម្តង។ នៅក្នុងផ្ទះមានគ្នាចំនួនបីនាក់ មានឈ្មោះ [redacted] សេងលី, សត្យា និងខ្លួន។ ពេលសមត្ថកិច្ចដកហូតមានថ្នាំញៀនមិនដឹងថា ជារបស់អ្នកណាគេទ និងលុយមួយដុំមិនដឹងចំនួនប៉ុន្មានជារបស់ឈ្មោះ [redacted] សត្យា។ ខ្លួនស្គាល់ឈ្មោះ [redacted] សត្យា មិនដល់មួយឆ្នាំផង ហើយស្គាល់ឈ្មោះ [redacted] សត្យា នៅពេលដែលគាត់ទៅលេងប្រទេសថៃ ហើយខ្លួនជាអ្នក

ជូនគាត់ដើរលេង។ ឈ្មោះ [redacted] នឿត និងឈ្មោះ ខុង ខុម ខ្លួនមិនស្គាល់នោះទេ ហើយឈ្មោះ [redacted] យ៉ាត់ក៏ខ្លួនមិនស្គាល់ទេ។ ខ្លួនស្គាល់ឈ្មោះ [redacted] សត្យា ជាអ្នករកស៊ីទិញលក់ដី។ ខ្លួនមិនបានដឹងថាថ្នាំញៀនដែលសមត្ថកិច្ចដកហូតនោះមិនដឹងជារបស់អ្នកណាទេ។ នៅមុនថ្ងៃដែលសមត្ថកិច្ចឃាត់ខ្លួននោះ គឺខ្លួនបានសម្រាកនៅក្នុងបន្ទប់ទទួលភ្ញៀវចំនួនបួនថ្ងៃជាប់ៗគ្នា ហើយឈ្មោះ សល់ សេងលី ជាអ្នកយកម្ហូបមកឱ្យខ្លួន។ ឈ្មោះ [redacted] សត្យា គាត់បានប្រាប់ខ្លួនថា មានមនុស្សចេញចូលមកផ្ទះគាត់ទំនាក់ទំនងទិញដី តែខ្លួនមិនបានឃើញដោយផ្ទាល់ទេ។ ផ្ទះរបស់ឈ្មោះ [redacted] សត្យា មិនចាក់សោរនោះទេគេអាចចេញចូលបាន។ ក្រៅពីពេលឈ្មោះ [redacted] សត្យា, ឈ្មោះ [redacted] សេងលី និងខ្លួនមានឈ្មោះ [redacted] ផេង គាត់ស្នាក់នៅទីនោះដែរ ហើយគាត់ជាប៉ូលីសពាក់ផ្កាយពីរ ហើយគាត់ជាអ្នកបើកឡានឱ្យឈ្មោះ [redacted] សត្យា។ ពេលដែលគាត់ឃាត់ខ្លួន ដកហូតពីខ្លួនមានខោអាវ ខ្សែកបន្តោងព្រះលិខិតឆ្លងដែន និងកាតមួយចំនួនទៀត។

ជនជាប់ចោទឈ្មោះ [redacted] នឿត បានឆ្លើយ៖ ខ្លួនមិនចាំថ្ងៃដែលសមត្ថកិច្ចឃាត់ខ្លួនទេ។ ខ្លួនជាអ្នកមើលចម្ការឱ្យបងស្រីជីដូនមួយឈ្មោះ [redacted] សត្យា ហើយខ្លួនដេកនៅផ្ទះរបស់គាត់ផង និងចម្ការរបស់គាត់ផង។ ឈ្មោះ [redacted] សត្យា មានមិត្តភក្តិរកស៊ីជាមួយឈ្មោះ ផេង ពួកគាត់រកស៊ីដី ធ្លីជាមួយគ្នា ទើបខ្លួនបានស្គាល់ឈ្មោះ ផេង បាន រយៈពេលប្រហែល ២ ទៅ ៣ខែដែរ មុនពេលឃាត់ខ្លួន។ ខ្លួន និងឈ្មោះ ផេង មិនដែលមានទំនាក់ទំនងគ្នាស្និតស្នាល គ្នាទេ ហើយនៅពេលដែលផឹកស៊ីខ្លួនមិនអង្គុយផឹកស៊ីជាមួយគាត់ដែរ ហើយឈ្មោះ ផេង មិនដែលឱ្យលុយខ្លួនចាយទេ ។ ខ្លួនធ្លាប់បានទៅលេងផ្ទះរបស់បងនឈ្មោះ ម៉េង នៅម្តុំដំដែកជាមួយបងស្រីឈ្មោះ [redacted] សត្យា ដែរ។ ឈ្មោះ ផេង ទៅដេកលេងនៅផ្ទះរបស់ឈ្មោះ [redacted] សត្យា ម្តងៗមានរយៈពេល ១យប់ ទៅ៣យប់ ទើបគាត់ចេញទៅវិញ ហើយគាត់មានបន្ទប់មួយសម្រាប់ដេក។ នៅថ្ងៃមិនចាំម៉ោងប្រហែល ៥ ជិត ៦យប់ ខ្លួនកំពុងតែធ្វើម្ហូបនៅផ្ទះឈ្មោះ [redacted] សត្យា ស្រាប់តែឈ្មោះ ផេង បានទូរស័ព្ទមកខ្លួនដោយប្រាប់ថា គាត់ភ្លេចកាបូបខោអាវនៅ បន្ទប់ដែលគាត់ដេក ហើយឱ្យខ្លួនយកឱ្យគាត់នៅស្ទោងផង ខ្លួនបានប្រាប់គាត់ថាខ្លួនគ្មានអីជិះទេ ឈ្មោះ ផេង បាន ប្រាប់ខ្លួនថាចាំគាត់ឱ្យឡានគេមកទទួល រួចខ្លួនបានឆ្លើយតបគាត់វិញថាបើកឡានមកយកហើយឱ្យដឹកកាបូបត ម្តងទៅភ្នំពេញនោះឈ្មោះ ផេង បានប្រាប់ខ្លួនថាឱ្យខ្លួនយកមកទើបខ្លួនបានហៅឈ្មោះ [redacted] ខុម ដែលជាអ្នកកាត់ ស្មៅនៅចម្ការបងខ្លួន។ ខ្លួនបានចូលទៅមើលក្នុងបន្ទប់របស់ឈ្មោះ ផេង ហើយបានឃើញកាបូបខោអាវពីរ ដោយឈ្មោះ ផេង បានឱ្យខ្លួនយកកាបូបមួយ[illegible]យកឱ្យគាត់នៅស្ទោង ហើយយកកាបូបមួយទៀតទៅទុកក្នុងទូរ របស់បងស្រីខ្លួនឈ្មោះ [redacted] [illegible] ទើបខ្លួនធ្វើតាមគាត់។ ស្រាប់តែម៉ោង ៦ល្ងាចមានមនុស្សពីរនាក់ជិះឡាន លិចស៊ីស ៣៣០ មក[illegible]ខ្លួន ទើបខ្លួនឡើងជិះឡានជាមួយឈ្មោះ [redacted] ខុម ឡើងមកស្ទោង ស្រាប់តែឈ្មោះ ផេង



Scanned with CamScanner

ឱ្យខ្លួនយកកាបូបខោអាវនោះមកដល់កំពង់ធំទៀត ក្រោយមកគាត់បានឱ្យខ្លួនយកមកឱ្យដល់ស្គន់ រហូតដល់ម៉ោង ១២ គាត់បានឱ្យខ្លួនយកកាបូបគាត់មកដល់ភ្នំពេញទៀត។ ពេលមកដល់ភ្នំពេញ ខ្លួនបានជួបឈ្មោះ ថេង នៅផ្ទះ សំណាក់នៅម្តុំកំបូល ប៉ុន្តែគាត់មិនបានយកកាបូបខោអាវពីខ្លួនទេ ដោយប្រាប់ថាចាំស្អែក ទើបខ្លួនក៏ព្រមចាំស្អែកតាមគាត់។ លុះស្អែកឡើងម៉ោង ៨ព្រឹក ឈ្មោះ ថេង បានជិះឡាន NISSAN NAVARA មកទទួលខ្លួនទៅផឹក កាហ្វេនៅ PTT ម្តុំវិថីឈ្នះៗបន្ទាប់មកប្រហែល ១៥នាទី ផឹកកាហ្វហើយឈ្មោះ ថេង បានឱ្យខ្លួនយកកាបូបគាត់ ចេញពីឡានហើយចាំគាត់នៅទីនោះបន្តិច គាត់ទៅយកគេមកផឹកកាហ្វេទៀតទើបខ្លួនកាន់កាបូបខោអាវឱ្យគាត់ នៅកន្លែងកាហ្វេនោះ ស្រាប់តែឈ្មោះ ថេង ចេញផុតប្រហែល ១៥នាទី ក៏មានសមត្ថកិច្ចមកចាប់ខ្លួន និងឈ្មោះ [redacted] ខុម ដែលកំពុងនៅផឹកកាហ្វជាមួយគ្នាតែម្តង។ នៅពេលដែលសមត្ថកិច្ចចាប់ខ្លួន ខ្លួនបានយកកាបូបមកចាក់ចេញមកសុទ្ធតែគ្រឿងញៀនដោយខ្លួនមិនបានដឹងថាក្នុងកាបូបនោះជាគ្រឿងញៀនទេ ខ្លួនដឹងត្រឹមតែខោអាវឈ្មោះ ថេង ប៉ុណ្ណោះ ព្រោះខ្លួនមិនដែលឆែកកាបូបឈ្មោះ ថេង ទេ។ នៅពេលសមត្ថកិច្ចឃាត់ខ្លួនបានហើយ ខ្លួនបាន ប្រាប់គាត់ថាខ្លួនគ្មានបក្ខពួកទេ គឺគ្រាន់តែយកកាបូបខោអាវមកឱ្យគេតែប៉ុណ្ណោះ ហើយមិនដឹងថាក្នុងកាបូបនោះ មានគ្រឿងញៀនដែរ ។ ក្នុងកាបូបនោះសមត្ថកិច្ចបានចាកចេញមកទើបខ្លួនឃើញមានគ្រឿងញៀនគ្រាប់ពណ៌ ក្រហមចំនួន ៣ដុំធំ និងថង់តូច។ ក្រោយពេលសមត្ថកិច្ចឃាត់ខ្លួនហើយបានពិនិត្យទឹកនោមខ្លួនដែរ ប៉ុន្តែគ្មានឃើញសារធាតុញៀនទេ។ បន្ទាប់មកសមត្ថកិច្ចបាននាំខ្លួនទៅសៀមរាបដើម្បីចាប់ខ្លួនឈ្មោះ [redacted] សត្យា ឈ្មោះ [redacted] ហេង (វុត ខាំសៃ) និងឈ្មោះ [redacted] សេងលី ដែលរស់នៅផ្ទះជាមួយបងស្រីខ្លួនឈ្មោះ [redacted] សត្យា ហើយ ខ្លួនស្គាល់ឈ្មោះ ពួកគាត់ទាំងអស់។ ខ្លួនមិនស្គាល់ឈ្មោះ [redacted] យ៉ាត់ ទេ។ ក្នុងរឿងនេះខ្លួនគិតថាឈ្មោះ ថេង គឺជាតឹញរបស់សមត្ថកិច្ចទើបសមត្ថកិច្ចចាប់ខ្លួន និងបងស្រីខ្លួនឈ្មោះ [redacted] សត្យា និងអ្នកដែលរស់នៅជាមួយគាត់។ ខ្លួន មិនដឹងថាថ្នាំញៀននៅក្នុងកាបូបឈ្មោះ ថេង យកមកពីណាទេ។ កន្លងមកខ្លួនធ្លាប់ឃើញឈ្មោះ ថេង ប្រើប្រាស់ កាបូបដែលគាត់ឱ្យខ្លួនយកឱ្យគាត់រហូត ។ ឈ្មោះ [redacted] ខាំសៃ ជាអ្នករកស៊ីដីធ្លីជាមួយបងស្រីខ្លួនឈ្មោះ [redacted] សត្យា ហើយគាត់ទាំងពីរមានទំនាក់ទំនងស្រឡាញ់គ្នាដែរ។ ចំណែកឈ្មោះ សល់ សេងលី ខ្លួនបានហៅគាត់មកពីកំពង់ចាម ដើម្បីបើកឡានឱ្យគេតែថៃដន្យក៏ត្រូវសមត្ថកិច្ចចាប់ខ្លួនដែរ។

ជនជាប់ចោទឈ្មោះ [redacted] ខុម បានឆ្លើយថា: នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង ល្ងាច មិនចាំម៉ោង ខ្លួនត្រូវបានសមត្ថកិច្ចចាប់ឃាត់ខ្លួនជាមួយឈ្មោះ [redacted] នឿត ដោយសមត្ថកិច្ចទាំងអស់នោះស្លៀdenក ពាក់ស៊ីវិលទាំងអស់គ្នា ហើយមានគ្នាច្រើន។ បន្ទាប់មកគេបាននាំខ្លួន និង [redacted] នឿត ទៅមន្ទីរប្រឆាំងគ្រឿងញៀន ដើម្បីសាកសួរព្រោះសមត្ថកិច្ចឆែកឆេរនៅក្នុងសាក់កាដូ



Scanned with CamScanner

ឃើញមានថ្នាំញៀនមួយកញ្ចប់ធំ។ កន្លងមកខ្លួននៅស្រុក ជាធម្មតាប្រកបមុខរបរកសិករធម្មតាទេ តែដោយស្គាល់ឈ្មោះ [redacted] នឿត នៅក្នុងហ្វេសប៊ុក ក៏ពឹងឱ្យជួយរក ការងារឱ្យធ្វើ ស្គាល់គ្នាបានរយៈពេលប្រហែលមួយសប្ដាហ៍ឈ្មោះ [redacted] នឿត បានប្រាប់ថាមានការងារធ្វើដោយ ឱ្យខ្លួនកាត់ស្មៅនៅផ្ទះបងស្រី ដែលមានអាស័យដ្ឋានស្ថិតនៅភូមិជ្រៃ ឃុំសណ្ដែក ស្រុកប្រាសាទបាគង ខេត្តសៀម រាប។ បន្ទាប់មកខ្លួនក៏បានទៅដល់ផ្ទះបងស្រីរបស់ឈ្មោះ [redacted] នឿត ហើយក៏បានស្នាក់នៅ និងធ្វើការងារកាត់ស្មៅនៅក្នុងផ្ទះនោះ។ នៅពេលដែលខ្លួនធ្វើការជាជាងកាត់ស្មៅនោះ ម្ចាស់ផ្ទះឈ្មោះ [redacted] សត្យា ថាឱ្យប្រាក់ខែខ្លួនចំនួន ២០០ ដុល្លារអាមេរិក ក្នុងមួយខែ ហើយខ្លួនក៏បានស្នាក់នៅតែម្ដង។ ចំពោះឈ្មោះ [redacted] នឿត ក៏បានស្នាក់ នៅក្នុងផ្ទះបងស្រីឈ្មោះ [redacted] សត្យានេះដែរ ចំពោះទំនាក់ទំនងរបស់ពួកគេគឺខ្លួនមិនដឹងនោះទេ។ កន្លងមកខ្លួនមិនដឹងថាឈ្មោះ [redacted] នឿត មានមុខរបររកស៊ីអ្វីទេ តែពេលខ្លួនបានមករស់នៅឯខេត្តសៀមរាប នៅក្នុងផ្ទះឈ្មោះ [redacted] សត្យា ក៏ឃើញវាទៅកាត់ស្មៅដូចខ្លួនដែរ។ ដោយឡែកចំពោះឈ្មោះ [redacted] សត្យា វិញក៏ខ្លួនពុំដឹងថាគាត់រក ស៊ីអ្វីដែរ។ ពេលខ្លួនស្នាក់នៅក្នុងផ្ទះរបស់ឈ្មោះ [redacted] សត្យា បានប្រហែលមួយសប្ដាហ៍ឈ្មោះ [redacted] នឿត ក៏បាន បបួលខ្លួនឡើងមកភ្នំពេញថាបានជាគ្នា ហើយខ្លួនក៏យល់ព្រមជាមួយវា។ ប៉ុន្តែនៅពេលឈ្មោះ [redacted] នឿត បបួល នោះគឺខ្លួនបានឮឈ្មោះ [redacted] នឿត ទាក់ទងជាមួយមិត្តភក្តិវាតាមទូរស័ព្ទថា យកខោអាវទៅឱ្យគេ យកទៅឱ្យត្រឹមស្ទោង ខេត្តកំពង់ធំ តែប៉ុណ្ណោះ ទើបខ្លួនព្រមទៅជាមួយ។ បន្ទាប់មកខ្លួនបានឃើញឈ្មោះ [redacted] នឿត បោះសាក់កាដូចូលក្នុងឡានឈ្នួល តខ្លួនពុំដឹងថានៅក្នុងសាក់កាដូនោះមានរបស់អ្វីខ្លះដែល។ បន្ទាប់មកខ្លួនក៏បានឡើង ឡានឈ្នួលមកជាមួយឈ្មោះ [redacted] នឿត នៅពេលល្ងាចម៉ោងប្រហែល ៦ល្ងាច ខ្លួនពុំបានយកអ្វីមកជាមួយទេ។ ខណៈពេលជិះតាមផ្លូវនោះឈ្មោះ [redacted] នឿត បានទាក់ទងទៅម្ចាស់សាក់កាដូ គាត់ថាគាត់ហួសមកដល់កំពង់ធំហើយ ហើយឱ្យហួសទៅតាមគាត់ទៅ។ ហើយឈ្មោះ [redacted] នឿត បានប្រាប់ខ្លួនគេហួសទៅដល់កំពង់ធំហើយ ដោយពួកខ្លួនរកមិនឃើញនៅត្រឹមស្ទោង ហើយពួកខ្លួនក៏ចេះតែហួសបន្តទៅមុខទៀត។ ពេលមកដល់កំពង់ធំ ក៏មិនបានជួបម្ចាស់សាក់កាដូដែលហើយបានទាន់ទៅគាត់ទៀត គាត់ថាមកហួសដល់ភ្នំពេញហើយ ឱ្យពួកខ្លួនមកភ្នំពេញមក ហើយពួកខ្លួនក៏មកទៅព្រោះចេះតែហួសទៅមុខហើយ។ រហូតមកដល់ភ្នំពេញ ពួកខ្លួនក៏បានស្នាក់ នៅផ្ទះសំណាក់មួយយប់ ដោយមកដល់នៅម៉ោងប្រហែល ៣-៤ យប់ ។ លុះព្រឹកឡើង ខ្លួនចុះមកហូបបាយនិងបានទិញបាយ ឱ្យឈ្មោះ [redacted] នឿត មួយប្រអប់។ លុះហូបបាយហើយ ម៉ោងប្រហែល ៨:៣០ នាទីព្រឹក ម្ចាស់សាក់កាដូបានទូរស័ព្ទ ហើយខ្លួន និងឈ្មោះ អាត នឿត បានយកសាក់កាដូចុះមកក្រោម ដើម្បីយកឱ្យគេ ហើយបានជួបគ្នា។ ពេលនោះម្ចាស់សាក់កាដូ បានហៅពួកខ្លួនឱ្យឡើងឡានទាំងអស់គ្នា ហើយពួកខ្លួនក៏ចូលក្នុងឡាន ទៅជាមួយដែរ។ បន្ទាប់មក គេដឹកពួកខ្លួនទៅកន្លែង

កាហ្វេ។ ផឹកបានបន្តិចស្រាប់តែមានគេរោរឡោចាប់ឃាត់ពួកខ្លួនតែម្តង។ ពេលសមត្ថកិច្ចចាប់ឃាត់ពួកខ្លួននោះគឺ ឱ្យពួកខ្លួនចូលក្នុងឡាន ហើយឱ្យយកសាក់កាដូឆែកឱ្យ ពួកខ្លួនមើល ឃើញមានខោអាវ និងឃើញមានថ្នាំញៀនមួយថង់ធំផងដែរ។

ជនជាប់ចោទឈ្មោះ [redacted] សេខលី បានឆ្លើយថា នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១ សមត្ថកិច្ចឃាត់ខ្លួន នៅចំណុចផ្លូវលំ ភូមិជ្រៃ ឃុំសណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប ខ្លួនពុំបានដឹងមូលហេតុនការឃាត់ខ្លួននោះទេ។ នៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២១ នៅចំណុចផ្លូវលំ ឃុំកណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប ខ្លួនកំពុងដេកអង្រឹងក្រោមដើមស្វាយ ភ្លាមនោះក៏មានសមត្ថកិច្ចចាក់ចូលក្នុងផ្ទះ ហើយយកកាំភ្លើងភ្ជង់ខ្លួន បាននិយាយថាឱ្យខ្លួនសហការជាមួយគាត់ ពេលនោះខ្លួនបានសួរសមត្ថកិច្ចវិញថាមានរឿងអីកើតឡើងសមត្ថកិច្ច ក៏បានឆ្លើយថាបន្តិចទៀតដឹង ហើយ បន្ទាប់មកក៏ឱ្យចូលខ្លួនក្នុងឡាន។ ចំណែកសមត្ថកិច្ចផ្សេងទៀតបាននាំឈ្មោះ [redacted] សត្យា និង ឈ្មោះ [redacted] ខាំសែ (ហៅ [redacted] ហេង) ដើម្បីធ្វើការឆែកឆេរនៅក្នុងផ្ទះរបស់គាត់ពេលសមត្ថកិច្ច ឆែកឆេរចប់សព្វគ្រប់ហើយគេឱ្យខ្លួនចេញពីឡាន ហើយសួរនាំ និងថតរូបភាព មានឃើញគ្រឿងញៀន ថតដាក់នៅលើតុ ក្រោយពីថតរូបរួចគេក៏បានបញ្ជូនខ្លួនមកស្នងការតែម្តង។ ពីមុនមកខ្លួនមិនស្គាល់ ឈ្មោះ [redacted] សត្យា នោះទេ ដឹងតែឮគេហៅ ពៅ តែខ្លួនស្គាល់ឈ្មោះ [redacted] នឿត ហើយឈ្មោះ [redacted] នឿត ស្នាក់នៅជាមួយគាត់ខ្លួន។ ស្គាល់ឈ្មោះ [redacted] នឿត រយៈពេល០២ឆ្នាំមកហើយ តែមិនសូវជាមាន ទំនាក់ទំនងគ្នាទេ ព្រោះបែកគ្នាយូរមកហើយ គឺទំនាក់ទំនងគ្នាតាមរយៈឆាត។ ខ្លួនមិនស្គាល់ឈ្មោះ [redacted] ខាំសែ (ហៅ [redacted] ហេង) និងឈ្មោះ [redacted] ខុម នោះទេ ហើយក៏មិនដឹងគាត់រកស៊ីអ្វីដែរ។ នៅមុនពេល ឃាត់ខ្លួនចំនួន ០២ ថ្ងៃឈ្មោះ [redacted] នឿត បានខលមកថា គេរើសអ្នកបើកឡាន បន្ទាប់មកខ្លួន ក៏ឡើងទៅតាមការហៅរបស់ឈ្មោះ [redacted] នឿត ដោយគ្មានកន្លែងស្នាក់នៅ ខ្លួនក៏ស្នាក់នៅផ្ទះរបស់ ឈ្មោះ [redacted] សត្យា តែម្តង។ នៅពេលសមត្ថកិច្ចឃាត់ខ្លួនដកហូតមាន កាតចាក់វ៉ាក់សាំង ០១, កាតធនាគារ ABA លុយខ្មែរ ១៥ម៉ឺនរៀល, ទូរស័ព្ទចំនួន០២គ្រឿងម៉ាក IPHONE 11 PRO MAX ០១ គ្រឿង, IPHONE XS MAX ០១គ្រឿង។ ខ្លួនបដិសេធមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ។ គ្រឿងញៀនដែលសមត្ថកិច្ចដកហូតគឺដកហូតពីផ្ទះឈ្មោះ [redacted] សត្យា

សាក្សីឈ្មោះ [redacted] សុខា ជាមន្ត្រីនគរបាលយុត្តិធម៌បានឆ្លើយថា៖ កាលពីថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង១០ និង៣០ នាទី កងកម្លាំងនគរបាលការិយាល័យនីតិវិធី (ក៧) នៃមន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន ដោយមានការដឹកនាំសម្របសម្រួលពីលោកព្រះរាជអាជ្ញារង [redacted] សាវ៉ាត បានចុះបង្ក្រាបបទល្មើស រក្សាទុក ដឹកជញ្ជូន ឬ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន នៅចំណុច ស្ថានីយ៍ប្រេងឥន្ធនៈ ភីធីធី តាមបណ្តោយផ្លូវវិមានឈ្នះឈ្នះ (ផ្លូវទំនិកប់ស្រូវ) សង្កាត់ចោមចៅ៣

ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដោយបានឃាត់ខ្លួនមនុស្សពីរនាក់ មានឈ្មោះ [redacted] នឿត និង [redacted] ខុម ព្រមទាំងដកហូតវត្ថុតាង គ្រឿងញៀនមេតំហ្វេតមីនប្រភេទគ្រាប់ មានអក្សរ WY ចំនួន ០៤កញ្ចប់ (កញ្ចប់ ៣ ធំ និង០១ តូច) មានទម្ងន់ ២០២៧,០៨ ក្រាម និងបានសាកសួរអ្នកទាំងពីរ ហើយបានសារភាពថាយកថ្នាំញៀន មកភ្នំពេញតាមរយៈការបញ្ជារបស់ឈ្មោះ [redacted] សត្យា ហើយ សមត្ថកិច្ចបានពន្លាតសមត្ថកិច្ចដែនដី ទៅខេត្តសៀមរាប និងបានបន្តឃាត់ខ្លួននៅវេលាម៉ោង ១៧ និង០៥ នាទីនាថ្ងៃខែឆ្នាំដដែល ដោយឃាត់ខ្លួនបានមនុស្សចំនួន០៣ នាក់ទៀត (មានឈ្មោះ [redacted] សត្យា ឈ្មោះ [redacted] ខាំសែ និងឈ្មោះ [redacted] សេងលី) ព្រមទាំងដកហូតបានវត្ថុតាង គ្រឿងញៀនមេតំហ្វេតាមីន ប្រភេទគ្រាប់ មានអក្សរ WY ចំនួន ០៥កញ្ចប់ធំ មានទម្ងន់ ៣០៤៨,៧១ ក្រាម និងបានបញ្ជូន ទៅការិយាល័យនីតិវិធី នៃមន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន ចាត់ការបន្ត។ មុននឹងឈានទៅដល់ការ ឃាត់ខ្លួននៅការ៉ាសាំង ភីធីធី គឺធ្វើឡើងតាមរយៈភ្នាក់ងារសម្ងាត់ A7.09 ដែលបានផ្តល់ពត៌មានពីការ ជួញដូរគ្រឿងញៀន ដោយទាក់ទងអោយខាងកម្លាំងយើងទាក់ទងទិញក្នុងតម្លៃ មួយគីឡូតម្លៃ ១៨០០ (មួយពាន់ប្រាំបីរយ) ដុល្លារ ដោយអោយទិញនៅសៀមរាប តែកម្លាំងយើងពិបាកចុះទៅបង្ក្រាប នៅសៀមរាប បានប្រើអោយភ្នាក់ងារអូសទាញដើម្បីធ្វើការទិញដូរនៅភ្នំពេញវិញ ហើយកម្លាំងបាន បង្ក្រាបនៅទីតាំងនោះតែម្តង។ ក្រោយពេលឃាត់ខ្លួនជនទាំងពីរខាងលើ បានសារភាពថាមេធំ នៅសៀមរាប ហើយកម្លាំងបានសហការណ៍និងពន្លាតសមត្ថកិច្ចដែនដី ជាមួយសមត្ថកិច្ចមូលដ្ឋាន ទីនោះ និងតំណាងអយ្យការសៀមរាប បានចូលធ្វើការឆែកឆេរ នៅទីតាំងផ្ទះគ្មានលេខ ផ្លូវលំ ភូមិជ្រៃ ឃុំកណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប ជាផ្ទះរបស់ឈ្មោះ [redacted] សត្យា និងបានរក ឃើញគ្រឿងញៀនមេតំហ្វេតមីនប្រភេទគ្រាប់ មានអក្សរ WY ចំនួន ០៥កញ្ចប់ធំ ហើយបានឃាត់ ខ្លួនមនុស្សបីនាក់ (មានឈ្មោះ [redacted] សត្យា ឈ្មោះ [redacted] ខាំសែ និងឈ្មោះ [redacted] សេងលី) ។ ចំពោះការ ឆែកឆេរនោះមានការចូលរួមពីព្រះរាជអាជ្ញារង សមត្ថកិច្ចមូលដ្ឋានខេត្តសៀមរាប មន្ត្រីភូមិឃុំ និងសាមីខ្លួនម្ចាស់ផ្ទះឈ្មោះ [redacted] សត្យា និងមានការឯកភាពពីម្ចាស់ផ្ទះផងដែរ។

ក្រឡាបញ្ជីអានកំណត់ហេតុចាប់យកសម្ភារៈ និងវត្ថុតាងលេខ ០៨៨ ក.ណ.ហ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២១ របស់ឈ្មោះ [redacted] នឿត ។

ក្រឡាបញ្ជីអានកំណត់ហេតុចាប់យកសម្ភារៈ និងវត្ថុតាងលេខ ០៩១ ក.ណ.ហ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២១ របស់ឈ្មោះ [redacted] ខុម។

ក្រឡាបញ្ជីអានកំណត់ហេតុចាប់យកសម្ភារៈ និងវត្ថុតាងលេខ ០៩៨ ក.ណ.ហ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២១ របស់ឈ្មោះ [redacted] សត្យា ។

ក្រឡាបញ្ជីអានកំណត់ហេតុចាប់យកសម្ភារៈ និងវត្ថុតាងលេខ ១០១ ក.ណ.ហ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២១ របស់ឈ្មោះ [redacted] ខាំសែ ។

ក្រឡាបញ្ជីអានកំណត់ហេតុចាប់យកសម្ភារៈ និងវត្ថុតាងលេខ ១០៤ ក.ណ.ហ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២១ របស់ឈ្មោះ [redacted] សេងលី។

ក្រឡាបញ្ជីអានកំណត់ហេតុទទួលវត្ថុតាងលេខ ២០០៩ រ.វ.ត ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២១ របស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងរាជធានីភ្នំពេញ។

ក្រឡាបញ្ជីបានអានលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ៣៣៨៦៣/២១ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១ របស់មន្ទីរពិសោធន៍នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលបានដកហូតពីជនជាប់ចោទឈ្មោះ [redacted] នឿត, [redacted] ខុម, [redacted] សត្យា, [redacted] ខាំសែ និងឈ្មោះ [redacted] សេងលី បង្ហាញថាសំណាក នៅក្នុងស្រោមសំបុត្របិទជិត មានហត្ថលេខាគណៈកម្មការ និងស្នាមមេដៃឈ្មោះ [redacted] នឿត, [redacted] ខុម, [redacted] សត្យា, [redacted] ខាំសែ និងឈ្មោះ [redacted] សេងលី ជាគ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះមេតំហ្វេតាមីន ដែលមានកម្រិតភាពសុទ្ធ ១៧.៥៦% នៃទម្ងន់សរុប រាស្ថិតក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀនដូចមានចែងលម្អិត ក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថ្កោលទោស**

ក្រោយពីបានពិនិត្យឯកសារនៅក្នុងសំណុំរឿង និងស្តាប់ចម្លើយរបស់ជនជាប់ចោទ តំណាងអយ្យការ យល់ឃើញថា តាមចម្លើយសារភាពរបស់ឈ្មោះ [redacted] នឿត, [redacted] ខុម, [redacted] ខាំសែ នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ មានភាពស៊ីសង្វាក់គ្នាជាមួយឯកសាររបស់មន្ត្រីនគរបាលយុត្តិធម៌ ដែលអាចបញ្ជាក់បានថាមានអង្គហេតុ រក្សាទុក ដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដែលបានប្រព្រឹត្តចាប់តាំងពីឆ្នាំ២០១៨ រហូតដល់ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២១ ប្រាកដមែន។ ឃើញថាជនជាប់ចោទទាំងអស់បានឆ្លើយបដិសេធថានៅដំណាក់កាលស៊ើបសួរ និងជំនុំជម្រះ ដោយបានបដិសេធចម្លើយនៅដំណាក់កាលសមត្ថកិច្ច និងគ្រឿងញៀនដែលបានដកហូត ក៏ដូចជាស្នាមមេដៃលើវត្ថុតាង ថាគ្មានមូលដ្ឋានច្បាស់លាស់ និងពុំមានបង្ហាញភស្តុតាងជាឯកសារសម្ភារៈ និងសាក្សីណាមួយផង ដើម្បីគាំទ្រការបដិសេធរបស់ខ្លួនដែលឆ្លើយនិងផ្តិតមេដៃលើឯកសារ [illegible] ម្យ៉ាងវិញទៀត ជនជាប់ចោទក៏មិនបានបង្ហាញភស្តុតាងណាមួយ តាមាករឆ្លើយបំភ្លឺ [illegible]ចំពោះមុខនគរបាលយុត្តិធម៌ ក៏ដូចជាការផ្តិតស្នាមមេដៃនៅនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ផង [illegible]ក្រៅឆន្ទៈរបស់ខ្លួន ឬការចាប់បង្ខំលើរូបរាងកាយចខ្លួន ឬ សមាជិកគ្រួសារណាមួយរបស់ [illegible] ហេតុដូចនេះ អយ្យការយល់ឃើញថាការឆ្លើយដោះសាររបស់ជនជាប់ចោទ គឺមិនត្រឹមត្រូវទេ។

យល់ឃើញថា តាមលទ្ធផលកោសល្យវិច្ច័យគ្រឿងញៀនលេខ ៣៣៨៦៣/២១ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១ របស់មន្ទីរពិសោធន៍នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន គឺជាគ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះមេតំហ្វេតាមីន ដែលមានកម្រិតភាពសុទ្ធ ១៧.៥៦% នៃទម្ងន់សរុប វាស្ថិតក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀនដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

យល់ឃើញថា អំពើរបស់ជាប់ចោទទាំងអស់ដែលបានទិញគ្រឿងញៀនពីប្រទេសថៃ ដើម្បីលក់បន្តនៅក្នុងប្រទេសកម្ពុជា ដើម្បីទទួលប្រាក់ចំណេញទើបត្រូវបានច្បាប់បញ្ញត្តិជាអំពើ រក្សាទុក ដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន។

យល់ឃើញថា ជនជាប់ចោទនីតិជនមានស្មារតីគ្រប់គ្រាន់ និងមិនមានសញ្ញាណណាមួយ ឬឯកសារណាមួយដែលបញ្ជាក់ថាពួកខ្លួនជាជនវិប្បល្លាស់ស្មារតីទាំងសរុង ឬមួយផ្នែក ក៏ដូចជាមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវ។

ហេតុដូចនេះ តំណាងអយ្យការ យល់ឃើញថាមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ លើជនជាប់ចោទឈ្មោះ [redacted] នឿត, [redacted] ខុម , [redacted] ខាំសៃ, [redacted] សត្យា និងឈ្មោះ [redacted] សេងលី ពីបទ រក្សាទុក ដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅក្នុងប្រទេសកម្ពុជា អំឡុងឆ្នាំ២០១៨ រហូតដល់ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២២ តាមបញ្ញត្តិមាត ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ ស្នើសុំប្រធានក្រុមប្រឹក្សាពិនិត្យសម្រេចទៅតាមផ្លូវច្បាប់។

មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានការពារ សឹម សត្យា

ឆ្លងតាមត្រួតពិនិត្យសំណុំរឿង ការសាកសួរដេញដោល និងចម្លើយជនជាប់ចោទទាំងប្រាំនាក់បានឆ្លើយបដិសេធ ចម្លើយដែលបានឆ្លើយនៅនគរបាលក្រសួងមហាផ្ទៃ។ តមាចម្លើយ [redacted] នឿត ឃើញថាគញរឿងញៀនទាំងបីកន្លែងនោះគឺខ្លួនមិនបានដឹងនោះទេ ទីមួយនៅខេត្តព្រះវិហារ គឺទៅយកតាមការបញ្ជាររបស់ឈ្មោះ [redacted] ផេង ទីពីរ គឺអង្គហេតុចាប់ខ្លួននៅភ្នំពេញ គឺពួកគេមិនដឹងថាក្នុងកាបូបជាគ្រឿងញៀន គឺយកកាបូបទៅឱ្យឈ្មោះ [redacted] ផេង ហើយបានយកមកពីក្នុងបន្ទប់របស់ឈ្មោះ ធួក ផេង ទីបីគឺដកយកពីក្នុងបន្ទប់របស់ឈ្មោះ [redacted] សត្យា តែតាមចម្លើយរបស់ឈ្មោះ [redacted] នឿត ថាឈ្មោះ [redacted] ផេង ជាអ្នកឱ្យយកទៅទុកក្នុងបន្ទប់របស់ឈ្មោះ [redacted] សត្យា។ តាមចម្លើយរបស់ឈ្មោះ [redacted] សត្យា បាមឆ្លើយបដិសេធថាគាត់មិនបានប្រើឈ្មោះ [redacted] នឿត [illegible]ទៅផ្ទេរអោយទៅយកថ្នាំឱ្យខ្លួននោះទេ ។ បើតាមចម្លើយរបស់ [redacted] នឿត បានបញ្ជាក់ថាឈ្មោះ [illegible] អោយយកថង់តវ៉ាន់ដាក់លើឡាន គេមិនបានដឹងថាជាអ្វីនោះទេ គឺតាមការបញ្ជាររបស់ឈ្មោះ [redacted] ផេង ហេតុនេះ ឈ្មោះ [redacted] ផេង គឺជាម្ចាស់នៃបទល្មើសដែលបង្កើតជាអង្គហេតុ

ហើយទំលាក់កំហុសឱ្យជនទាំងប្រាំ ដោយអោយកាន់យកកាបូបរបស់ឈ្មោះ [redacted] ថេង ទាំងអស់។ ស្នើសុំឱ្យតុលាការ បើកការស៊ើបអង្កេតលើឈ្មោះ [redacted] ថេង ដើម្បីស្វែងរកថាតើនរណាជាម្ចាស់គ្រឿងញៀនពិតប្រាកដ។

**មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្ដីសន្និដ្ឋានការពារ សល់ សេងលី**

ក្រោយពីបានពិនិត្យលើសំណុំរឿង ចម្លើយរបស់ជនជាប់ចោទ **ឃើញថាទាក់ទងទៅនឹងវិធានការ** ញ៉ុះញ៉ង់ តាមរយៈឯកសារ និងចម្លើយរបស់ជនជាប់ចោទ ឃើញថា ពួកគាត់មិនបានដឹងរឿងអ្វីនោះទេ ដោយឡែកឈ្មោះ [redacted] ថេង មិនមានចម្លើយមកតុលាការនោះទេ។ ហើយថ្នាំញៀននោះគឺជារបស់ឈ្មោះ [redacted] ថេង តើការប្រើវិធានការញ៉ុះញ៉ង់នេះមានភាពត្រឹមត្រូវឬទេ? តាមមាត្រា ៤០ នៃ **រក្សាទុក ដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្នុងប្រទេសកម្ពុជា អំឡុងឆ្នាំ២០១៨ រហូតដល់ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២២ **ឃើញថាពុំមានអង្គហេតុសម្រាប់**ចោទប្រកាន់កូនក្ដីខ្លួននោះទេ។ ដោយកូនក្ដីខ្លួននៅផ្ទះ ហើយចោទថា រក្សាទុក គ្រឿងញៀន សួរថាគ្រឿងញៀននោះនៅឯណា? ហើយដឹកជញ្ជូនកូនក្ដីខ្លួនក៏មិនបានដឹកជញ្ជូនដែរ សួរថាតើកូនក្ដីខ្លួនបានប្រព្រឹត្តដោយរបៀបណា? សំណូមពរឱ្យតុលាការមេត្តាចាត់របៀបស៊ើបសួរលើឈ្មោះ [redacted] ថេក ថាតើជាថ្នាំញៀន របស់អ្នកណា។

**មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្ដីសន្និដ្ឋានការពារ [redacted] នឿត, [redacted] ខុម [redacted] ខាំសែ**

បន្ទាប់ពីបានសិក្សាលើសំណុំរឿង សិក្សាចម្លើយនៅនិតិវិធីស៊ើបសួរ និងនៅក្នុងអង្គសវនាការបានបញ្ជាក់ឱ្យឃើញថា កូនក្ដីរបស់ខ្លួនទាំងបីរូប មិនមានសញ្ញាណណាមួយ ដែលបានពាក់ព័ន្ធនិងគ្រឿងញៀនឡើង។ ជាក់ស្ដែងឈ្មោះ [redacted] ខាំសែ ដែលបានស្នាក់នៅជាមួយឈ្មោះ [redacted] សត្យា មិនបានដឹងថាមានកាបូបគ្រឿងញៀននោះទេ គឺគាត់មកដើម្បីទេសចរណ៍ប៉ុណ្ណោះ។ ដោយឡែកឈ្មោះ [redacted] ខុម ក៏ជាអ្នកស្នាក់នៅជាមួយឈ្មោះ [redacted] នឿត នៅភ្នំពេញ ក៏មិនបានដឹងថាមានកាបូបរក្សាទុកគ្រឿងញៀននោះដែរ។ ម្យ៉ាងទៀតឈ្មោះ អាត នឿត ដែលត្រូវបានគេចោទប្រកាន់ថាបានកាន់កាបូបដែលមានផ្ទុកគ្រឿងញៀនយកទៅដាក់ចូលទៅក្នុងបន្ទប់របស់ឈ្មោះ [redacted] សត្យា និងបានយកទៅតំគេត្តតាមចម្លើយ គឺឈ្មោះ [redacted] ថេង ជាភ្នាក់ងារញ៉ុះញង់ឱ្យយកកាបូបតាំងតែពីដើមឡើយដែលឈ្មោះ [redacted] នឿត មិនបានដឹងឡើយ។ ទាំងនេះសរបញ្ជាក់ឱ្យឃើញថា កូនក្ដីទាំងបីនាក់ ពីបញ្ហារគ្រឿងញៀននោះទេ ហេតុនេះនាំឱ្យមានបញ្ហារថ្មីដែរម្ចាស់ថ្នាំញៀនគឺឈ្មោះ [redacted] ថេង ស្នើសុំប្រធានក្រុមប្រឹក្សាបើកការស៊ើបអង្កេតលើឈ្មោះ [redacted] ថេង ដើម្បីផ្ដល់យុត្តិធម៌ឱ្យកូនក្ដីខ្លួន។

## ជនជាប់ចោទនិយាយសម្តីចុងក្រោយ

ជនជាប់ចោទឈ្មោះ [redacted] សត្យា បានសុំឱ្យតុលាការរកយុត្តិធម៌ និងដោះលែងឱ្យមានសេរីភាព ។

ជនជាប់ចោទឈ្មោះ [redacted]ាំសែ បានសុំឱ្យតុលាការដោះលែងឱ្យមានសេរីភាព ។

ជនជាប់ចោទឈ្មោះ [redacted] ឡឿត បានសុំឱ្យតុលាការរកយុត្តិធម៌ និងដោះលែងឱ្យមានសេរីភាព ។

ជនជាប់ចោទឈ្មោះ [redacted] ខុម បានសុំឱ្យតុលាការរកយុត្តិធម៌ និងដោះលែងឱ្យមានសេរីភាព ។

ជនជាប់ចោទឈ្មោះ [redacted] សេងលី បានសុំឱ្យតុលាការរកយុត្តិធម៌ និងដោះលែងឱ្យមានសេរីភាព ។

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សី

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

ក្រោយពីបានពិនិត្យភស្តុតាង

ក្រោយពីបានពិភាក្សា ពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## <u>សំអាងហេតុ</u>

១. កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង១០ និង៣០នាទី សមត្ថកិច្ចនគរបាលការិយាល័យនីតិវិធី (ក៧) នៃមន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន ពិតជាបានចុះបង្ក្រាបបទល្មើសរក្សាទុក ដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន នៅចំណុចស្ថានីយ៍ប្រេងឥន្ធនៈភីធីធី (PTT) ផ្លូវវិមានឈ្នះ១ (ផ្លូវទំនប់ស្រូវ) សង្កាត់ចោមចៅ៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឃាត់ខ្លួនជនត្រូវចោទចំនួន០២នាក់ មានឈ្មោះ [redacted] ឡឿត ភេទប្រុស និងឈ្មោះ [redacted] ខុម ភេទប្រុស ដកហូតបានវត្ថុតាងគ្រឿងញៀនប្រភេទមេតំហ្វេតាមីន ប្រភេទគ្រាប់ក្រហមមានសញ្ញាអក្សរ WY ចំនួន ០៤កញ្ចប់ (ធំ០៣ និងតូច០១) សមត្ថកិច្ចបានធ្វើការសាកសួរ ទើបដឹងថាមានមេក្លោងនៅខេត្តសៀមរាប រហូតដល់វេលាម៉ោង១៧ និង០៥នាទី នាថ្ងៃដដែល នៅចំណុចផ្ទះគ្មានលេខ ផ្លូវលំ ភូមិជ្រៃ ឃុំកណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប សមត្ថកិច្ចបានបន្តឃាត់ខ្លួនមេក្លោង និងបក្ខពួករបស់ជនត្រូវចោទចំនួន ០៣ នាក់ទៀតរួមមាន៖ ឈ្មោះ [redacted] សត្យា ភេទស្រី ឈ្មោះ [redacted] ខាំសែ ហៅ លីម ហេង ភេទប្រុស ជនជាតិថៃ សញ្ជាតិថៃ និងឈ្មោះ [redacted] សេងលី ភេទប្រុស និងបានដកហូតវត្ថុតាងជាគ្រឿងញៀនមេតំហ្វេតាមីនប្រភេទគ្រាប់មានសញ្ញាអក្សរWY បន្ថែមចំនួន០៥កញ្ចប់ធំ។ សមត្ថកិច្ចបាននាំជនត្រូវចោទចំនួន០៣នាក់ មកការិយាល័យប្រឆាំងគ្រឿងញៀន ធ្វើការសាកសួរបន្ថែម។ សរុបថ្នាំគ្រាប់ពណ៌ក្រហម(WY)មានទម្ងន់ សរុប [illegible],៧៩ ក្រាម (ប្រាំគីឡូនិងចិតសិបប្រាំកៀសចិតសិបប្រាំបួនក្រាម) ជាប្រភេទមេតំហ្វេតាមីន។

ក្រោយពីការធ្វើការសាកសួរទទួលបានលទ្ធផលថាជនត្រូវចោទឈ្មោះ [redacted] សត្យា ក្នុងឆ្នាំ២០១៨ ខ្លួនបានស្គាល់ឈ្មោះ [redacted] យ៉ាត់ ភេទប្រុស ភេទប្រុស អាយុ៥០ឆ្នាំ នៅពេលរកស៊ីជួញឈើជាមួយគ្នា ហើយបានបែកគ្នារហូតដល់ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ ដោយឈ្មោះ [redacted] យ៉ាត់ បានទូរស័ព្ទមកខ្លួន ហើយបាននិយាយពីការលក់ថ្នាំញៀន មេតំហ្វេតាមីនប្រភេទគ្រាប់ ពីប្រទេសថៃមកកម្ពុជា។ លុះដល់ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២១ ខ្លួនបានឱ្យឈ្មោះ [redacted] នឿត ឡើងទៅប្រទេសថៃ ទៅជួបឈ្មោះ [redacted] យ៉ាត់ ដើម្បីទៅយកថ្នាំញៀនប្រភេទគ្រាប់ ០៨សុង ស្មើចំនួន ២៥ កញ្ចប់តូច ពីប្រទេសថៃមកកម្ពុជា។ លុះដល់ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២២១ មានម៉ូយម្នាក់នៅភ្នំពេញបាន ទូរស័ព្ទមកខ្លួនកម្មង់ទិញថ្នាំញៀនពីខ្លួនចំនួន ១០ប្រអប់ ខ្លួនបានឱ្យបក្ខពួកឈ្មោះ [redacted] នឿត និងឈ្មោះ [redacted] ខុម យកថ្នាំញៀននោះទៅឱ្យម៉ូយនៅភ្នំពេញ។ ស្រាប់តែនៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២១ សមត្ថកិច្ចបាននាំបក្ខពួកខ្លួនឈ្មោះ [redacted] នឿត និងឈ្មោះ [redacted] ខុម មកដល់ផ្ទះធ្វើការឃាត់ខ្លួន និងបក្ខពួកខ្លួនមានឈ្មោះ [redacted] ខាំសៃ ហៅ [redacted] ហេង និងឈ្មោះ [redacted] សេងលី ភេទប្រុស។ បន្ទាប់មកសមត្ថកិច្ចបានកសាងសំណុំរឿង បញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធីច្បាប់ ប្រាកដមែន។

២. នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] នឿត, [redacted] ខុម, [redacted] ខាំសៃ, [redacted] សត្យា និងឈ្មោះ [redacted] សេងលី បានឆ្លើយបដិសេធថា ខ្លួនពុំបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់របស់តំណាងអយ្យការ ក៏ដោយក៏ប៉ុន្តែចម្លើយនេះគ្រាន់តែជាការឆ្លើយដោះសារប៉ុណ្ណោះ ព្រោះថារបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ បង្ហាញថាជនជាប់ចោទពិតជាបានរក្សាទុក ដឹកជញ្ជូន និងទិញគ្រឿងញៀន ដើម្បីយកមកលក់បន្តប្រាកដមែន ដែលស្របទៅនឹងភស្តុតាងផ្សេងៗទៀតដែលមាននៅក្នុងសំណុំរឿងផងដែរ ។

៣. ជនជាប់ចោទ ជានីតិជន និងជាសមត្ថជនដែលមានសមត្ថភាពទទួលខុសត្រូវព្រហ្មទណ្ឌបានពោលគឺ ជនជាប់ចោទពិតជាមានស្មារតីយល់ដឹងពីផលវិបាក ដែលកើតចេញពីអំពើប្រព្រឹត្តរបស់ខ្លួន ។

៤. សកម្មភាពប្រព្រឹត្តរបស់ជនជាប់ចោទ បានបញ្ជាក់យ៉ាងច្បាស់ ពីចេតនាទុច្ចរិតក្នុងការរក្សាទុក ដឹកជញ្ជូន និងទិញគ្រឿងញៀន ដើម្បីលក់ទៅវិញយកចំណេញ ប្រាកដមែន។

៥. មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ខុម ភេទប្រុស អាយុ៤១ឆ្នាំ សញ្ជាតិខ្មែរ, ឈ្មោះ [redacted] នឿត ភេទប្រុស អាយុ៤២ឆ្នាំ សញ្ជាតិខ្មែរ, ឈ្មោះ [redacted] សត្យា ភេទស្រី អាយុ៣៨ឆ្នាំ សញ្ជាតិខ្មែរ, ឈ្មោះ [redacted] ខាំសៃ ហៅ [redacted] ហេង ភេទប្រុស អាយុ៥២ឆ្នាំ សញ្ជាតិថៃ , ឈ្មោះ [redacted] សេងលី ភេទប្រុស អាយុ៣៨ឆ្នាំ សញ្ជាតិខ្មែរ ពីបទ: **រក្សាទុក ដឹកជញ្ជូន និងជួញដូរ**

ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅក្នុងប្រទេសកម្ពុជា អំឡុងឆ្នាំ២០១៨ រហូតដល់ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៦. អំពើប្រព្រឹត្តរបស់ជនជាប់ចោទ បានធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់របៀបរៀបរយ សាធារណៈ និងសន្តិសុខសង្គម ។

៧. វត្ថុចាប់យករួមមាន៖

៧.១. វត្ថុចាប់យកគប្បីប្រគល់ឱ្យម្ចាស់ដើមវិញ

<u>ក. វត្ថុចាប់យកដែលដកហូតពីឈ្មោះ ស៊ឹម សត្យា</u>

១. លិខិតឆ្លងដែនប្រទេសកម្ពុជា (Passport) លេខ 0177983 របស់ឈ្មោះ [redacted] សត្យា ចំនួន ០១ (មួយ) ក្បាល។

២. លិខិតឆ្លងដែនប្រទេសកាណាដា (Passport) លេខ IM66T របស់ឈ្មោះ [redacted] សត្យា (SEM SATYA) ចំនួន ០១ (មួយ)ក្បាល ។

៣. លិខិតឆ្លងដែនប្រទេសកាណាដា (Passport) លេខ HG016S របស់ឈ្មោះ [redacted] សត្យា (SEM SATYA) ចំនួន ០១ (មួយ) សន្លឹក។

៤. អត្តសញ្ញាណប័ណ្ណខ្មែរលេខ 010629262 របស់ឈ្មោះ ស៊ឹម សត្យា ចំនួន ០១ (មួយ) សន្លឹក។

៥. សៀវភៅស្នាក់នៅលេខ 3047 របស់ឈ្មោះ [redacted] សត្យា ចំនួន ០១ (មួយ) ក្បាល។

៦. ប័ណ្ណបើកបរលេខ B.PP00032202 របស់ឈ្មោះ [redacted] សត្យា ចំនួន ០១ (មួយ) សន្លឹក។

៧. ប័ណ្ណចាក់វ៉ាក់សាំងកូវីដ-១៩ លេខ 1267320928 របស់ឈ្មោះ [redacted] សត្យា ចំនួន ០១ (មួយ) សន្លឹក។

<u>ខ.វត្ថុចាប់យកដែលដកហូតពីឈ្មោះ [redacted] ខាំសៃ ហៅ [redacted] ហេង</u>

១. លិខតឆ្លងដែនប្រទេសថៃ (Passport) លេខ AB3357289 របស់ឈ្មោះ [redacted] ហេង (ភាសាថៃ RUIT KHAMSAS) ចំនួន ០១(មួយ)ក្បាល។

២. អត្តសញ្ញាណប័ណ្ណសញ្ជាតិថៃលេខ 3420400092566 របស់ឈ្មោះ [redacted] ហេង (ឈ្មោះភាសាថៃ KIT KHMSAI) ចំនួន ០១(មួយ)សន្លឹក។

៣. ប័ណ្ណបើកបរម៉ូតូប្រទេសថៃលេខ 36000229 របស់ឈ្មោះ [redacted] ហេង (ភាសាថៃ RUIT KHAMSA) ចំនួន ០១(មួយ)សន្លឹក។

៤. ប័ណ្ណបើកបររថយន្តប្រទេសថៃលេខ 38001097 របស់ឈ្មោះ [redacted] ហេង (ភាសាថៃ RUIT KHAMSA) ចំនួន ០១(មួយ)សន្លឹក។

៥.ប័ណ្ណបើកបរលេខ 181000020 របស់ឈ្មោះ [redacted] ម៉ូនី (HUN MONY) ចំនួន ០១ (មួយ) សន្លឹក។

**គ.វត្ថុចាប់យកដែលដកហូតពី ឈ្មោះ [redacted] សេងលី**

១. អត្តសញ្ញាណប័ណសញ្ជាតិខ្មែរ 030521596 របស់ឈ្មោះ [redacted] សេងលី ចំនួន ០១ (មួយ) សន្លឹក។

២.ប័ណ្ណចាក់វ៉ាក់សាំងកូដ-១៩ លេខ 12177 របស់ឈ្មោះ [redacted] សេង ចំនួន ១មួយសន្លឹក។

**៧.២. វត្ថុចាប់យកគប្បីរីបអូស**

១.ទូរសព្ទចំនួន ០១(មួយ) គ្រឿង ម៉ាក Realme C12 IMEលេខ 8662180510018951 របស់ឈ្មោះ [redacted] ហេង។

២.ទូរសព្ទចំនួន ០១ (មួយ) គ្រឿង ម៉ាក Realme5pro IMEលេខ 861866042305294 របស់ឈ្មោះ [redacted] ហេង។

៣.ទូរសព្ទចំនួន ០១(មួយ)គ្រឿង ម៉ាក OPPOA54 IMEលេខ 868958050891316 របស់ឈ្មោះ [redacted] សត្យា។

៤.ទូរសព្ទចំនួន ០១(មួយ)គ្រឿង ម៉ាក Iphones6s IMEលេខ 355728077231477 របស់ឈ្មោះ [redacted] សត្យា។

៥.ទូរសព្ទចំនួន ០១(មួយ)គ្រឿង ម៉ាក Iphone 11 promax IMEលេខ 35394910177966 របស់ឈ្មោះ [redacted] សេងលី។

៦.ទូរសព្ទចំនួន ០១(មួយ)គ្រឿង ម៉ាក Iphone promax IMEលេខ 353095100464208 របស់ឈ្មោះ [redacted] សេងលី។

៧.ទូរសព្ទចំនួន ០១(មួយ)គ្រឿង ម៉ាក VIVO IMEលេខ : 86073704999757 របស់ឈ្មោះ [redacted] នៀត។

៨. ទូរសព្ទចំនួន ០១(មួយ)គ្រឿង ម៉ាក Realme5pro IMEលេខ 8658720433395751 របស់ឈ្មោះ [redacted] ខុម។

៩.កាតធនាគារអេប៊ីអេ (ABA BANK) ចំនួន ០៥(ប្រាំ)សន្លឹក របស់ឈ្មោះ [redacted] សត្យា (SEN SATYA) រួមមាន៖

-កាតធនាគារអេប៊ីអេ (VISA) លេខ 4286090124135425 ចំនួន ០១ (មួយ) សន្លឹក។

-កាតធនាគារអេប៊ីអេ (VISA) លេខ 4286090011409891 ចំនួន ០១ (មួយ) សន្លឹក។

-កាតធនាគារអេប៊ីអេ (VISA) លេខ 4585140010120508 ចំនួន ០១ (មួយ) សន្លឹក។

-កាតធនាគារអេប៊ីអេ (Union Pay) លេខ 6291440094043794 ចំនួន ០១ (មួយ) សន្លឹក។

-កាតធនាគារអេប៊ីអេ (Union Pay) លេខ 6233750020250326 ចំនួន ០១ (មួយ) សន្លឹក។

១០.កាតធនាគារការណាឌីយ៉ា (VISA) លេខ 4133388882605364 របស់ឈ្មោះ [redacted] សត្យា (SEM SATYA)ចំនួន ០១ (មួយ) សន្លឹក។

១១.កាតធនាគារស៊ីអាអិមប៊ី (CIMB BANK) លេខ 5046820000284287 របស់ ឈ្មោះ [redacted] សត្យា (SEN SATYA) ចំនួន ០១(មួយ)សន្លឹក។

១២.កាតធនាគារកម្ពុជាសាធារណៈលេខ 4705780000873312 របស់ឈ្មោះ [redacted] សត្យា (SEN SATYA) ចំនួន០១(មួយ)សន្លឹក។

១៣.សៀវភៅធនាគារកម្ពុជាសាធារណៈលេខ 0200230171013 របស់ឈ្មោះ [redacted] សត្យា (SEM SATYA) ចំនួន០១(មួយ)ក្បាល។

១៤.សៀវភៅធនាគារប្រទេសថៃលេខ 0498967086 របស់ឈ្មោះ [redacted] ហេង (ភាសាថៃ RUT KHAMSAI) ចំនួន ០១(មួយ)ក្បាល។

១៥.សៀវភៅធនាគារប្រទេសថៃលេខ 0738924002 របស់ឈ្មោះ [redacted] ហេង (ភាសាថៃ RUT KHAMSAI) ចំនួន ០១(មួយ)ក្បាល។

១៦.សៀវភៅធនាគារ ABA លេខ 002255602 របស់ឈ្មោះ [redacted] ម៉ូនី (HUN MONY) ចំនួន ០១ (មួយ) ក្បាល។

១៧.សៀវភៅធនាគារ PRINCE លេខ 110540 របស់ឈ្មោះ [redacted] ម៉ូនី (HUN MONY) ចំនួន ០១ (មួយ) ក្បាល។

១៨. សៀវភៅធនាគារ May Bank លេខ AOY7218 របស់ឈ្មោះ [redacted] ម៉ូនី (HUN MONY) ចំនួន ០១ (មួយ) ក្បាល។

១៩. សៀវភៅធនាគារកម្ពុជាសាធារណៈលេខ 0200230171(6 របស់ឈ្មោះ [redacted] ម៉ូនី (HUN MONY) ចំនួន០១ (មួយ) ក្បាល។

២០.កាបូបស្ពាយចំនួន ០១ (មួយ) ម៉ាក Pedro ពណ៌ខ្មៅ។

<u>ហេតុដូច្នេះសម្រេច</u>

ផ្តន្ទាទោស:

ឈ្មោះ [redacted] ខុម ភេទប្រុស អាយុ៤១ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ៣០ (សាមសិប) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៨០ ០០០ ០០០ (ប៉ែតសិបលាន) រៀល។

ខ. ឈ្មោះ [redacted] នឿត ភេទប្រុស អាយុ៤២ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ៣០ (សាមសិប) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៨០ ០០០ ០០០ (ប៉ែតសិបលាន) រៀល។

គ. ឈ្មោះ [redacted] សត្យា ភេទស្រី អាយុ៣៨ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ៣០ (សាមសិប) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៨០ ០០០ ០០០ (ប៉ែតសិបលាន) រៀល។

ឃ.ឈ្មោះ [redacted]ាំសៃ ហៅ [redacted] ហេង ភេទប្រុស អាយុ៥២ឆ្នាំ សញ្ជាតិថៃ ដាក់ពន្ធនាគារកំណត់ ៣០ (សាមសិប) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៨០ ០០០ ០០០ (ប៉ែតសិបលាន) រៀល។

ង. ឈ្មោះ [redacted] សេងលី ភេទប្រុស អាយុ៣៨ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ៣០ (សាមសិប) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៨០ ០០០ ០០០ (ប៉ែតសិបលាន) រៀល។

ពីបទ: **រក្សាទុក ដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្នុងប្រទេសកម្ពុជា អំឡុងឆ្នាំ២០១៨ រហូតដល់ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២. វត្ថុចាប់យករួមមាន៖

២.១. វត្ថុចាប់យកត្រូវប្រគល់ឱ្យម្ចាស់ដើមវិញ

**<u>ក. វត្ថុចាប់យកដែលដកហូតពីឈ្មោះ ស៊ឹម សត្យា</u>**

១. លិខិតឆ្លងដែនប្រទេសកម្ពុជា (Passport) លេខ 0177983 របស់ឈ្មោះ [redacted] សត្យា ចំនួន ០១ (មួយ) ក្បាល។

២. លិខិតឆ្លងដែនប្រទេសកាណាដា (Passport) លេខ IM66T របស់ឈ្មោះ [redacted] សត្យា (SEM SATYA) ចំនួន ០១ (មួយ)ក្បាល ។

៣. លិខិតឆ្លងដែនប្រទេសកាណាដា (Passport) លេខ HG016S របស់ឈ្មោះ [redacted] សត្យា (SEM SATYA) ចំនួន ០១ (មួយ) សន្លឹក។

៤. អត្តសញ្ញាណប័ណ្ណខ្មែរលេខ 010629262 របស់ឈ្មោះ [redacted] សត្យា ចំនួន ០១ (មួយ) សន្លឹក។

៥. សៀវភៅស្នាក់នៅលេខ 3047 របស់ឈ្មោះ [redacted] សត្យា ចំនួន ០១ (មួយ) ក្បាល។

៦. ប័ណ្ណបើកបរលេខ B.PP00032202 របស់ឈ្មោះ [redacted] សត្យា ចំនួន ០១ (មួយ) សន្លឹក។

៧. ប័ណ្ណចាក់វ៉ាក់សាំងកូវីដ-១៩ លេខ 1267320928 របស់ឈ្មោះ [redacted] សត្យា ចំនួន ០១ (មួយ) សន្លឹក។

**<u>ខ. វត្ថុចាប់យកដែលដកហូតពីឈ្មោះ [redacted] ខាំសៃ ហៅ [redacted] ហេង</u>**

១. លិខិតឆ្លងដែនប្រទេសថៃ (Passport) លេខ AB3357289 របស់ឈ្មោះ [redacted] ហេង (ភាសាថៃ RUIT KHAMSAS) ចំនួន ០១(មួយ)ក្បាល។

២. អត្តសញ្ញាណប័ណ្ណសញ្ជាតិថៃលេខ 3420400092566 របស់ឈ្មោះ [redacted] ហេង (ឈ្មោះភាសាថៃ KIT KHMSAI) ចំនួន ០១(មួយ)សន្លឹក។

៣. ប័ណ្ណបើកបរម៉ូតូប្រទេសថៃលេខ 36000229 របស់ឈ្មោះ [redacted] ហេង (ភាសាថៃ RUT KHAMSA) ចំនួន ០១(មួយ)សន្លឹក។

៤.ប័ណ្ណបើកបររថយន្តប្រទេសថៃលេខ 38001097 របស់ឈ្មោះ [redacted] ហេង (ភាសាថៃ RUT KHAMSA) ចំនួន ០១(មួយ)សន្លឹក។

៥.ប័ណ្ណបើកបរលេខ 181000020 របស់ឈ្មោ[redacted] ម៉ូនី (HUN MONY) ចំនួន ០១ (មួយ) សន្លឹក។

គ.វត្ថុចាប់យកដែលដកហូតពី ឈ្មោះ [redacted] សេងលី

១. អត្តសញ្ញាណប័ណសញ្ជាតិខ្មែរ 030521596 របស់ឈ្មោះ [redacted] សេងលី ចំនួន ០១ (មួយ) សន្លឹក។

២.ប័ណ្ណចាក់វ៉ាក់សាំងកូវីដ-១៩ លេខ 12177 របស់ឈ្មោះ [redacted] សេង ចំនួន ឱ្យមួយសន្លឹក។

២.២. វត្ថុចាប់យកត្រូវរឹបអូស

១.ទូរសព្ទចំនួន ០១(មួយ) គ្រឿង ម៉ាក Realme C12 IMEលេខ 8662180510018951 របស់ឈ្មោះ [redacted] ហេង។

២.ទូរសព្ទចំនួន ០១ (មួយ) គ្រឿង ម៉ាក Realme5pro IMEលេខ 861866042305294 របស់ឈ្មោះ [redacted] ហេង។

៣.ទូរសព្ទចំនួន ០១(មួយ)គ្រឿង ម៉ាក OPPOA54 IMEលេខ 868958050891316 របស់ឈ្មោះ [redacted] សក្សា។

៤.ទូរសព្ទចំនួន ០១(មួយ)គ្រឿង ម៉ាក Iphones6s IMEលេខ 355728077231477 របស់ឈ្មោះ [redacted] សត្យា។

៥.ទូរសព្ទចំនួន ០១(មួយ)គ្រឿង ម៉ាក Iphone 11 promax IMEលេខ 35394910177966 របស់ឈ្មោះ [redacted] សេងលី។

៦.ទូរសព្ទចំនួន ០១(មួយ)គ្រឿង ម៉ាក Iphone promax IMEលេខ 353095100464208 របស់ឈ្មោះ [redacted] សេងលី។

៧.ទូរសព្ទចំនួន ០១(មួយ)គ្រឿង ម៉ាក VIVO IMEលេខ : 86073704999757 របស់ឈ្មោះ [redacted] នឿង។

៨. ទូរសព្ទចំនួន ០១(មួយ)គ្រឿង ម៉ាក Realme5pro IMEលេខ 8658720433395751 របស់ឈ្មោះ [redacted] ខុម។

៩.កាតធនាគារអេប៊ីអេ (ABA BANK) ចំនួន ០៥(ប្រាំ)សន្លឹក របស់ឈ្មោះ [redacted] សត្យា (SEN SATYA) រួមមាន៖

-កាតធនាគារអេប៊ីអេ (VISA) លេខ 4286090124135425 ចំនួន ០១ (មួយ) សន្លឹក។

-កាតធនាគារអេប៊ីអេ (VISA) លេខ 4286090011409891 ចំនួន ០១ (មួយ) សន្លឹក។

- កាតធនាគារអេប៊ីអេ (VISA) លេខ 4585140010120508 ចំនួន ០១ (មួយ) សន្លឹក។

-កាតធនាគារអេប៊ីអេ (Union Pay) លេខ 6291440094043794 ចំនួន ០១ (មួយ) សន្លឹក។

-កាតធនាគារអេប៊ីអេ (Union Pay) លេខ 6233750020250326 ចំនួន ០១ (មួយ) សន្លឹក។

១០.កាតធនាគារការណាឌីយ៉ា (VISA) លេខ 4133388882605364 របស់ឈ្មោះ [redacted] សត្យា (SEM SATYA)ចំនួន ០១ (មួយ) សន្លឹក។

១១.កាតធនាគារស៊ីអាអិមប៊ី (CIMB BANK) លេខ 5046820000284287 របស់ ឈ្មោះ [redacted] សត្យា (SEN SATYA) ចំនួន ០១(មួយ)សន្លឹក។

១២.កាតធនាគារកម្ពុជាសាធារណៈលេខ 4705780000873312 របស់ឈ្មោះ [redacted] សត្យា (SEN SATYA) ចំនួន០១(មួយ)សន្លឹក។

១៣.សៀវភៅធនាគារកម្ពុជាសាធារណៈលេខ 0200230171013 របស់ឈ្មោះ [redacted] សត្យា (SEM SATYA) ចំនួន០១(មួយ)ក្បាល។

១៤.សៀវភៅធនាគារប្រទេសថៃលេខ 0498967086 របស់ឈ្មោះ [redacted] ហេង (ភាសាថៃ RUT KHAMSAI) ចំនួន ០១(មួយ)ក្បាល។

១៥.សៀវភៅធនាគារប្រទេសថៃលេខ 0738924002 របស់ឈ្មោះ [redacted] ហេង (ភាសាថៃ RUT KHAMSAI) ចំនួន ០១(មួយ)ក្បាល។

១៦.សៀវភៅធនាគារ ABA លេខ 002255602 របស់ឈ្មោះ [redacted] មុំនី (HUN MONY) ចំនួន ០១ (មួយ) ក្បាល។

១៧.សៀវភៅធនាគារ PRINCE លេខ 110540 របស់ឈ្មោះ [redacted] មុំនី (HUN MONY) ចំនួន ០១ (មួយ) ក្បាល។

១៨.សៀវភៅធនាគារ May Bank លេខ AOY7218 របស់ឈ្មោះ [redacted] មុំនី (HUN MONY) ចំនួន ០១ (មួយ) ក្បាល។

១៩. សៀវភៅធនាគារកម្ពុជាសាធារណៈលេខ 0200230171(6 របស់ឈ្មោះ [redacted] ម៉ូនី (HUN MONY) ចំនួន០១ (មួយ) ក្បាល។

២០.កាបូបស្ពាយចំនួន ០១ (មួយ) ម៉ាក Pedro ពណ៌ខ្មៅ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២ ។

បើកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ** **ចៅក្រមប្រឹក្សា** **ចៅក្រមប្រឹក្សា** **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

ហត្ថលេខា និងត្រា: [redacted]

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

បានឃើញ

ថ្ងៃចន្ទ ១៣រោច ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

កំពង់ឆ្នាំង, ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ ២០២២

**ក្រឡាបញ្ជីសវនាការ**

[redacted]

[redacted]